ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៣២៤ ព.ណ.ស.ជ.ពកព

ថ្ងៃអង្គារ ៥កើត ខែពិសាខ ឆ្នាំមមីរ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៦


# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌានឹងរៀបចំ «ពិព័រណ៍គ្រឿងសមុទ្រលើកទី២ ( The Second Edition of Seafood Expo Bharat - SEB 2026 )» ពីថ្ងៃទី១-៣ ខែកក្កដា ឆ្នាំ២០២៦ នៅទីក្រុង Chennai រដ្ឋ Tamil Nadu ប្រទេសឥណ្ឌា។

ពិព័រណ៍នេះនឹងមានស្តង់ចំនួន៣២៥ ហើយរំពឹងថាមានគណៈប្រតិភូធុរកិច្ចឥណ្ឌា និងបរទេសចូលរួមប្រមាណ៥០០០នាក់។ បន្ថែមពីនេះ កម្មវិធីក៏នឹងរៀបចំជូនគណៈប្រតិភូចូលរួម កម្មវិធីជំនួបធុរកិច្ច ទស្សនកិច្ចរោងចក្រកែច្នៃគ្រឿងសមុទ្រ និងកសិដ្ឋានជលផលផងដែរ។ ក្នុងន័យនេះ ភាគីឥណ្ឌាបានអញ្ជើញក្រុមហ៊ុននាំចូលគ្រឿងសមុទ្រចំនួន១០ និងអ្នកចូលរួមតាំងពិព័រណ៍ចំនួន១០ស្តង់ផ្សេងទៀត ក្នុងផ្នែក seafood processors, aquaculture and processing machinery manufacturers, និង aquaculture/processing input supplier សម្រាប់ចូលរួមរៀបចំពន្លាកម្ពុជា នៅក្នុងព្រឹត្តិការណ៍ខាងលើផងដែរ។ ភាគីឥណ្ឌានឹងទទួលចេញថ្លៃសំបុត្រយន្តហោះទៅ-មក មិនលើស២០០០ដុល្លារអាមេរិក ( សម្រាប់តែមួយនាក់ក្នុងមួយក្រុមហ៊ុន ) ការស្នាក់នៅ និងការធ្វើដំណើរក្នុងស្រុក សម្រាប់តំណាងក្រុមហ៊ុននាំចូលគ្រឿងសមុទ្រ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមពិព័រណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមក លោក S. Asok Kumar, នាយករង តាមរយៈ WhatsApp: +917276009600 និងអ៊ីម៉ែល៖ b2bmeets@ mpeda.gov.in ឬ asokkumar@mpeda.gov.in ឬ លោក Sreejith P.T., ជំនួយការនាយក តាមរយៈ WhatsApp: +917736464984 និងអ៊ីម៉ែល៖ sreejith@mpeda.gov.in៕

សូមអរគុណ!

https://go.gov.kh/moc/n86xec
GO.gov.KH

Ministry of Commerce
N°1.3.24 MOC.D/TPEA

Phnom Penh, 21 April 2026

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all traders and the public that the Ministry of Commerce & Industry, Government of India will organize "The Second Edition of Seafood Expo Bharat – SEB 2026", to be held from 1-3 July 2026 at the Chennai City, Tamil Nadu, India.

This fair will feature 325 booths and is expected to attract around 5,000 Indian and foreign business delegates. In addition, the program will also provide opportunities for delegates to participate in a business meeting program, visit seafood processing plants and aquaculture farms. Meanwhile, the India side proposes to invite 10 seafood importers and 10 other exhibitors, including seafood processors, aquaculture and processing machinery manufacturers, and aquaculture/ processing input suppliers to participate in and set up the Cambodian Pavilion at the above event. The organizer will cover round-trip airfare ( up to USD 2,000 for one representative per company ), accommodation and domestic travel for representatives of seafood importers.

In this regard, the Ministry of Commerce, as a facilitator, would like to invite Cambodian traders and the public who are interested in aforementioned event to contact Mr. S. Asok Kumar, Deputy Director via WhatsApp: +917276009600 and Email: b2bmeets@mpeda.gov.in / asokkumar@mpeda.gov.in or Mr. Sreejith P.T., Assistant Director via WhatsApp: +917736464984, and Email: sreejith@mpeda.gov.in.

https://go.gov.kh/moc/n86xec
GO.gov.KH

THANK YOU!